ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សំណុំរឿងព្រហ្មទណ្ឌ
លេខ ២៧៥១
ចុះថ្ងៃទី ២៤-១១-២០០៩
-ជំនុំជម្រះលេខ ៤៣៥
ចុះថ្ងៃទី ០៣-០៣-២០១០
-សាលក្រមព្រហ្មទណ្ឌ
លេខ ១៥០ "ក្រ១"
ចុះថ្ងៃទី ២១-១២-២០១០

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការនៃសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១០ ដោយមានសមាសភាពជំនុំជម្រះដូចតទៅ ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា

-លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ២៧៥១ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ដែលមាន ៖

-ជនជាប់ចោទឈ្មោះ [redacted] វីរៈ ហៅ វិន ភេទ ប្រុស អាយុ ២០ ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរជាងរោងពុម្ព កើតនៅភូមិកោះឃ្លោក ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត មានទីលំនៅមុនពេលឃាត់ខ្លួនផ្ទះជួល [redacted] ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ស ម្តាយឈ្មោះ [redacted] រ៉ រៀនថ្នាក់ទី១០ នៅលីវ ទោសពីមុនគ្មាន។

ឃាត់ខ្លួនថ្ងៃទី ២២-១១-២០០៩ និងឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣០១៤ ត.ព្រ ចុះថ្ងៃទី ២៥-១១-២០០៩

លោក [redacted] ពិសិដ្ឋ និងលោក [redacted] សុជាតិ ជាមេធាវីការពារជនជាប់ចោទ

ជាប់ចោទពីបទ **រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ** ប្រព្រឹត្តនៅផ្ទះសំណាក់ចេកមាស (ក្រោយសាលាបាក់ទូក) ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ បទល្មើស ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ...



Scanned by CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទ ស្រី អាយុ ៤០ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted] ស្រុកគីរីវង់ ខេត្តតាកែវ មុខរបរស់អាងការ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្តីឈ្មោះ [redacted]។

-ជនរងគ្រោះឈ្មោះ [redacted]យ៉ា ភេទ ស្រី អាយុ ១៤ ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិឡូរី ឃុំកាក្លុង ស្រុកដូនកែវ ខេត្តតាកែវ ទីលំនៅបច្ចុប្ប[redacted] ស្រុកគីរីវង់ ខេត្តតាកែវ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted]។

លោក [redacted] **ជាទិត** និងកញ្ញា [redacted] **ម៉ាំណែត** ជាមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ

-**បានឃើញ** របាយការណ៍សំយោគលេខ ៣៦៧/០៩ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ៣៦០ អ.យ.ដ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១០ របស់លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ១២ ដ.ជ.រ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១០ របស់លោក [redacted] ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** សាលក្រមចាត់របៀបលេខ ០៩ "ក្រ១" ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាបង្គាប់ឱ្យនាំជនជាប់ចោទទៅសាលាដំបូងរាជធានីភ្នំពេញ លេខ ១៩៧១៨ ត.ព្រ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ វេលាម៉ោងប្រហែល ៦ ល្ងាច ជនរងគ្រោះឈ្មោះ [redacted]យ៉ា ភេទស្រី អាយុ ១៤ ឆ្នាំ បានទូរស័ព្ទហៅឈ្មោះ [redacted] វីរៈ ហៅ វិន ភេទប្រុស អាយុ ២០ ឆ្នាំ ឱ្យមកយកខ្លួននៅកន្លែងចេនឡា ពេលនោះឈ្មោះ [redacted]វីរៈ ក៏បានជិះម៉ូតូឌុបមកយកឈ្មោះ យ៉ា រួចនាំគ្នាទៅហូបបាយនៅមុខចេនឡា បន្ទាប់មកក៏បានទៅរកជួលផ្ទះសំណាក់ដេក បន្ទាប់ពីរកផ្ទះសំណាក់ដេកហើយ គឺផ្ទះសំណាក់ចេកមាស (ក្រោយសាលាបាក់ទូក) រួចក៏បានទុកឥវ៉ាន់នៅទីនោះ រួចក៏នាំគ្នាជិះម៉ូតូទៅញ៉ាំបាយ និងសាច់គោអាំងនៅស្តុបទេពផន រួចហើយក៏នាំគ្នាទៅគេងនៅផ្ទះសំណាក់វិញ នៅយប់នោះឈ្មោះ [redacted] វីរៈ ក៏បានដេកគ្រែមួយពីរនាក់ជាមួយឈ្មោះ យ៉ា (ជនរងគ្រោះ) ហើយបានរួមរ័កជាមួយឈ្មោះ យ៉ា ពីរដង លើកទី១ នៅវេលាម៉ោងប្រហែល២ លើកទី២ វេលាម៉ោងប្រហែល ៥ភ្លឺ មុនពេលរួមរ័កឈ្មោះ យ៉ា បានដោះសំលៀកបំពាក់ខ្លួនឯង ហើយពេលរួមរ័កនោះឈ្មោះ យ៉ា ពុំមានស្រែកអ្វីទេ។ ពេលរួមរ័កនោះឈ្មោះ វីរៈ បានដាក់ប្រដាប់ភេទចូលទៅក្នុងប្រដាប់ភេទរបស់ឈ្មោះ យ៉ា ទាំងពីរលើក។ លុះដល់ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ វេលាម៉ោង ១០ ព្រឹក ឈ្មោះ យ៉ា បានទូរស័ព្ទហៅឈ្មោះ វីរៈ ឱ្យទៅជួបនៅម្តុំផ្សារថ្មី ពេលទៅដល់ត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តង។ ...



Scanned by CamScanner

-ជនជាប់ចោទឈ្មោះ [redacted]វីរៈ ហៅ វិន ឆ្លើយថា : នៅថ្ងៃទី ២០-១១-២០០៥ វេលាម៉ោង ៦ ល្ងាច ពេលនោះ ឈ្មោះ [redacted]យ៉ា ភេទ ស្រី អាយុ ១៦ ឆ្នាំ បានទូរស័ព្ទមកខ្ញុំឱ្យទៅយកគេនៅមុខចេនឡា ពេលខ្ញុំទៅដល់ក៏នាំគ្នាជិះម៉ូតូឌុបទៅហូបបាយនៅទល់មុខការ៉ាស់សាំងចេនឡា ។ ក្រោយពីហូបបាយហើយក៏នាំគ្នាជិះម៉ូតូឌុបទៅរកផ្ទះសំណាក់ចេកមាស ហើយខ្ញុំឱ្យឈ្មោះ [redacted]យ៉ា មុតឥវ៉ាន់នៅផ្ទះសំណាក់ហើយក៏ជិះម៉ូតូឌុបទៅហូបអីនៅម្តុំទេពផន ។ បន្ទាប់មកក៏មានមិត្តខ្ញុំពីរនាក់ទូរស័ព្ទមក គឺឈ្មោះ ក្រន និងឈ្មោះ រដ្ឋា ឱ្យមកហូបបាយជាមួយដែរ ហើយបែកគ្នាទៅផ្ទះរៀងៗខ្លួន ។ ចំណែកឯខ្ញុំ និងឈ្មោះ យ៉ា បានមកផ្ទះសំណាក់ដដែលវិញ ពេលនោះគឺឈ្មោះ យ៉ា មិនហ៊ានដេកម្នាក់ឯង ក៏ឱ្យខ្ញុំដេកជាមួយ ហើយខ្ញុំពុំបានរួមភេទជាមួយឈ្មោះ យ៉ា ទេ រហូតដល់ម៉ោង ៦ជិតភ្លឺ ខ្ញុំក៏ងើបឡើងទៅធ្វើការនៅបឹងសាឡាង ។ លុះដល់ថ្ងៃទី ២១-០១-០៥ វេលាម៉ោង ១១ ឈ្មោះ យ៉ា បានទូរស័ព្ទមកខ្ញុំឱ្យមកយកទៅផ្ទះសំណាក់ ( មិនស្គាល់ឈ្មោះ) ទល់មុខប៉ុស្តិ៍ផ្សារថ្មី២ ពេលនោះខ្ញុំបានខ្ចីម៉ូតូមិត្តភក្តិជិះជាមួយឈ្មោះ ក្រន ហើយទៅយកឈ្មោះ យ៉ា រួចខ្ញុំក៏ជិះតាមមាត់ទន្លេទាំងអស់គ្នា ហើយក៏បាននិយាយជាមួយឈ្មោះ យ៉ា ឱ្យត្រលប់ទៅផ្ទះវិញ ប៉ុន្តែឈ្មោះ យ៉ា ពុំព្រមទៅទេ ទោះជាវាយគេងាប់ក៏គេមិនទៅដែរ ។ ឈ្មោះ យ៉ា បានឱ្យខ្ញុំជូនជួយទិញម៉ូតូម៉ាក ICON មួយគ្រឿងឱ្យគេ ហើយលុយជារបស់ឈ្មោះ យ៉ា ។ ពេលដែលខ្ញុំទិញបានហើយ ខ្ញុំក៏ទុកម៉ូតូឱ្យឈ្មោះ យ៉ា ជិះជាមួយឈ្មោះ ក្រន ហើយខ្ញុំក៏ត្រឡប់មកធ្វើការធម្មតាវិញ ។ ពេលល្ងាចម៉ោង ៦ ខ្ញុំបានទូរស័ព្ទទៅឈ្មោះ ក្រន ឱ្យយកម៉ូតូមកឌុបខ្ញុំទៅហូបអីនៅនាគសមុទ្រជាមួយឈ្មោះ ក្រន ខ្ញុំ . យ៉ា . ដោរ និងម្នាក់ទៀតមិនស្គាល់ឈ្មោះ រហូតដល់ម៉ោង ៩យប់ ក៏នាំគ្នាទៅ SPARK ជិតទូតចិនទាំងអស់គ្នា ។ ពេលនោះមិត្តភក្តិម្នាក់មិនស្គាល់មុខ បានហៅឈ្មោះ យ៉ា ទៅរាំលេងក្នុង SPARK ហើយខ្ញុំចាំនៅក្រៅជាមួយឈ្មោះ ក្រន ហើយយូរពេករួចខ្ញុំក៏ត្រលប់មកផ្ទះវិញ លុះស្អែកឡើងថ្ងៃទី ២២-១១-២០០៥ វេលាម៉ោង ១១ថ្ងៃត្រង់ ខ្ញុំក៏បានទូរស័ព្ទឈ្មោះ យ៉ា មកយកម៉ូតូនៅការ៉ាស់សាំងផ្សារថ្មី ពេលនោះសមត្ថកិច្ចក៏ឃាត់ខ្លួនខ្ញុំតែម្តងជាមួយឈ្មោះ យ៉ា ។ ខ្ញុំសូមបដិសេធចម្លើយនៅសមត្ថកិច្ចនគរបាល ។-

-លោក [redacted] ជាមន្ត្រីនគរបាលយុត្តិធម៌ឆ្លើយថា : ខ្ញុំបានទទួលពាក្យបណ្តឹងបាត់កូន ដែលត្រូវម្តាយប្តឹង ក្រោយមកទើបដឹងថា នាងដើរតាម [redacted]រៈ ក្រោយមកទើបចាប់បាននៅលើស្ពាន ក្រោយមកជនរងគ្រោះឆ្លើយថាឈ្មោះ [redacted] វីរៈ បានចាប់រំលោភនាងពីរដងបានសម្រេច ក្រោយមកទើបម្តាយរបស់នាងនាំទៅធ្វើកោសល្យវិច័យ ។ ខ្ញុំបានសួរនាំលើជនរងគ្រោះថា បានដើរហូបចុក និងគេងនៅផ្ទះសំណាក់ ហើយរួមភេទបានពីរដង ។ ខ្ញុំពុំបានសួរនាំដល់ការចេញ[redacted]ទ ។

-កំណត់ហេតុស្តាប់ចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted]យ៉ា នៅចំពោះមុខចៅក្រមស៊ើបសួរថា : នាងខ្ញុំមកលេងបុណ្យអុំទូកនៅភ្នំពេញ កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ ស្នាក់នៅផ្ទះអ៊ំនាងខ្ញុំនៅបឹងសាឡាង ខណ្ឌទួលគោក ហើយនៅថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ពេលនោះគឺឈ្មោះ [redacted]វីរៈ ហៅ វិន៸

បានទូរស័ព្ទពីលេខ [redacted] មកនាងខ្ញុំថាសុំរាប់អាន ហើយនាងខ្ញុំឆ្លើយតបវិញថា នាងខ្ញុំនៅក្មេងមិនទាន់រាប់អានទេ ហើយគេឆ្លើយថា ក្មេងក៏រាប់អានដែរ ពេលនោះអ៊ំនាងខ្ញុំនៅក្បែរនោះ រួចខ្ញុំក៏បិទទូរស័ព្ទ ក្រោយមកនៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឈ្មោះ [redacted] វីរៈ បានជួបនាងខ្ញុំនៅមុខសាលាបឹងសាឡាង ហើយក៏នាំនាងខ្ញុំទៅផ្សារសុវណ្ណាប្រហែលកន្លះម៉ោង ពេលនោះឪពុកនាងខ្ញុំបានទូរស័ព្ទមកឱ្យនាងខ្ញុំត្រឡប់ទៅផ្ទះវិញ ហើយខ្ញុំក៏ត្រឡប់ទៅផ្ទះនៅតាកែវវិញ។ នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ពេលនោះនាងខ្ញុំបានលួចខ្សែក ខ្សែដៃ របស់ម្ដាយនាងខ្ញុំ ព្រោះខ្ញុំខឹងគាត់បានដកទូរស័ព្ទពីខ្ញុំ ហើយនាងខ្ញុំក៏យកខ្សែក មកលក់នៅផ្សារទម្លាប់ បានប្រាក់ចំនួន ១ ៩៦០ ០០០រៀល ( មួយលានហាសិបប្រាំមួយម៉ឺនរៀល) ហើយនាងខ្ញុំក៏ឡើងជិះឡានឈ្នួលមកភ្នំពេញ ពេលមកដល់បេនឡានចេនឡា ពេលនោះនាងខ្ញុំបានទូរស័ព្ទមករកឈ្មោះ [redacted] វីរៈ ហើយគេបានប្រាប់នាងខ្ញុំថា ចាំឱ្យពួកម៉ាកមកយក ក្រោយក៏ឃើញឈ្មោះ វិន មកទទួលនាងខ្ញុំ ពេលនោះឈ្មោះ វិន បាននាំនាងខ្ញុំទៅញ៉ាំបាយនៅជិតចេនឡា ពេលញ៉ាំបាយហើយរួចក៏ជិះម៉ូតូឌុបទៅជួលបន្ទប់ផ្ទះសំណាក់ចេកមាស ក្រោយសាលាបាក់ទូក ហើយក៏នាំនាងខ្ញុំទៅទិញខោអាវនៅផ្សារសូរិយា រួចក៏នាំនាងខ្ញុំទៅហូបអីនៅហាងម្ជិះនៅជិតវិមានឯករាជ្យ ដោយមានមិត្តភក្តិរបស់ វិន ប្រាំនាក់ ហើយស្រីគឺនាងខ្ញុំតែម្នាក់ ហូបរហូតដល់ម៉ោង ១១យប់ ហើយក៏នាំគ្នាទៅក្លឹបឌិស្កូនៅក្បែរហាងម្ជិះរហូតដល់ម៉ោង ១២ និង០០នាទីយប់ ក៏ចេញមកទាំងអស់គ្នា រួចក៏មកហូបបបរនៅជិតផ្សារស៊ីធី ពេលដែលហូបចុកទាំងប៉ុន្មានគឺនាងខ្ញុំជាអ្នកចេញលុយឱ្យទាំងអស់។ ក្រោយមកពួកម៉ាករបស់ឈ្មោះ វិន ក៏បែកគ្នាទៅផ្ទះ ហើយឈ្មោះ [redacted] វីរៈ បានឱ្យម៉ូតូគេឌុបនាងខ្ញុំទៅដេកនៅផ្ទះសំណាក់ ដោយចូលដល់ក្នុងបន្ទប់ពេលនោះនាងខ្ញុំស្មានតែឈ្មោះ វិន ឱ្យនាងខ្ញុំដេកនៅផ្ទះសំណាក់ម្នាក់ឯង ហើយនាងខ្ញុំបានបិទបន្ទប់ តែមិនបានចាក់សោ ក្រោយមក វិន បានរុញទ្វារបន្ទប់រួចចូលទៅដែរ ហើយមិនទាន់បើកភ្លើងផងរួចឈ្មោះ វិន បានរុញនាងខ្ញុំទៅលើគ្រែ ហើយបានដោះសំលៀកបំពាក់នាងខ្ញុំចេញអស់ ហើយឈ្មោះ វិន ក៏បានដោះខោអាវចេញអស់ដែរ ហើយឡើងដេកពោបពីលើនាងខ្ញុំ [redacted] ចក៏ដាក់ចូលរន្ធភេទនាងខ្ញុំធ្វើចលនារួមភេទប្រហែល ១៥នាទី ទើបចេញទឹកដាក់ចូលក្នុងរន្ធភេទនាងខ្ញុំ ដោយមិនមានពាក់ស្រោមអនាម័យទេ។ ក្រោយមកប្រហែល ៥នាទី ឈ្មោះ [redacted] វីរៈ ហៅ វិន បានរួមភេទជាមួយនាងខ្ញុំ ២ដងទៀត ពេលនោះនាងខ្ញុំបានប្រាប់ឈ្មោះ វិន ថាឈឺ ហើយគេប្រាប់នាងខ្ញុំថាទ្រាំទៅ រួចនាងខ្ញុំក៏ឡើងទៅងូតទឹកមានឈាមហូរ រួចស្លៀកខោអាវដេកជាមួយគ្នារហូតដល់ជិតភ្លឺ ពេលនោះនាងខ្ញុំបានយកទូរស័ព្ទមកមើលម៉ោងប្រហែលម៉ោងបីជិតភ្លឺ ហើយឈ្មោះ [redacted] វីរៈ ហៅ វិន ក៏បានអោបថើបនាងខ្ញុំ រួចដោះសំលៀកបំពាក់នាងខ្ញុំចេញ ឡើងពោបពីលើនាងខ្ញុំ [redacted] ដាក់ចូលរន្ធភេទនាងខ្ញុំ ហើយធ្វើចលនារួមភេទ រយៈពេលប្រហែល ១០ នាទី រួចក៏ចេញទឹកកាមដាក់ចូលរន្ធភេទនាងខ្ញុំម្ដងទៀត ហើយនាងខ្ញុំក៏ងូតទឹកស្លៀកពាក់ខោអាវ ហើយប្រហែលម៉ោង ៦ជាង ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ហើយឈ្មោះ វិន បាននាំនាងខ្ញុំមកហូបបាយនៅមុខសាលាបាក់ទូក។ ~



Scanned by CamScanner

-ក្រឡាបញ្ជីអានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] នៅចំពោះមុខចៅក្រមស៊ើបសួរថា : នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កូននាងខ្ញុំឈ្មោះ [redacted] យ៉ា ភេទ ស្រី អាយុ ១៤ ឆ្នាំ បានចេញពីផ្ទះលួចយកខ្សែកបីខ្សែ និងខ្សែដៃមួយខ្សែ មាសសុទ្ធទម្ងន់បួនតំលឹងកន្លះ។ ព្រោះនាងខ្ញុំបានដកយកទូរស័ព្ទពីកូននាងខ្ញុំ។ លុះម៉ោងប្រហែល ៨ និង ០០នាទីយប់ ពេលនោះមានគេប្រាប់នាងខ្ញុំថា កូននាងខ្ញុំបានជិះឡានតាក់ស៊ីសមកភ្នំពេញ ហើយនាងខ្ញុំមានការសង្ស័យក៏ទៅចាក់សោរទូមើល ស្រាប់តែឃើញរបស់អស់ ពេលនោះនាងខ្ញុំក៏ជិះឡានមកភ្នំពេញទាំងយប់ លុះព្រឹកឡើងថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ នាងខ្ញុំបានដាក់ពាក្យបណ្តឹងនៅការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។ នាងខ្ញុំសំណូមពរ សុំទាមទារសំណងជំងឺចិត្តចំនួន ១០ ០០០ដុល្លា ( មួយម៉ឺនដុល្លាអាមេរិក ) និងសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់។

-ក្រឡាបញ្ជីអានចម្លើយរបស់សាក្សីឈ្មោះ [redacted] នៅចំពោះមុខចៅក្រមស៊ើបសួរថា : នាងខ្ញុំបំរើការងារនៅមន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ ផ្នែករោគស្ត្រី។ លទ្ធផលព័ត៌មាននៅក្នុងចំណុចទី១-៦ នៃឯកសារចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១០ របស់មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ នោះគឺជាព័ត៌មានដែលបានមកពីជនរងគ្រោះប្រាប់ផ្ទាល់មកនាងខ្ញុំ។ ក្នុងករណីនេះ គឺអាចកើតមានក្នុងករណីដែលការរួមភេទនោះ គូភាគីបានប្រើប្រាស់បច្ចេកទេសក្នុងការរួមភេទ។

-ក្រឡាបញ្ជីអានចម្លើយរបស់សាក្សីឈ្មោះ [redacted] នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ថា : នៅល្ងាចថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ មិត្តរបស់ខ្ញុំឈ្មោះ វិន ធ្វើការនៅរោងពុម្ព និងជួលផ្ទះនៅម្តុំហាងសុខសប្បាយផ្លូវម៉ៅសេទុង បានហៅខ្ញុំឱ្យមកហូបអីនៅម្តុំស្តុបទេពផន ពេលខ្ញុំមកដល់ក៏ឃើញមិត្តខ្ញុំមានគ្នាបួននាក់ផ្សេងទៀត ក្នុងនោះមានស្រីម្នាក់ឈ្មោះ យ៉ា ( តែគេប្រាប់ខ្ញុំថាឈ្មោះ លីន ) ដែលឈ្មោះ វិន និង យ៉ា នេះស្គាល់គ្នាពេលហូប ហើយក៏បែកគ្នាទៅផ្ទះរៀង១ខ្លួន ដោយឈ្មោះ វិន និងឈ្មោះ យ៉ា ទៅជាមួយគ្នា។ រហូតនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឈ្មោះ វិន និងឈ្មោះ យ៉ា ហើយម្នាក់ទៀតឈ្មោះ គ្រន មិត្តភក្តិ វិន បាននាំគ្នាទៅផ្ទះជួលរបស់ខ្ញុំនៅជិតកុងទីណង់តាល ហើយឈ្មោះ វិន ក៏ទៅធ្វើការដោយឱ្យឈ្មោះ គ្រន ជូនឈ្មោះ យ៉ា ទៅទិញខោអាវ ទិញហើយក៏ត្រឡប់មកផ្ទះខ្ញុំវិញ ដូរសំលៀកបំពាក់ ឈ្មោះ វិន ត្រឡប់មកវិញដែរក៏នាំគ្នាចេញទៅរកផ្ទះជួលឱ្យឈ្មោះ យ៉ា ស្នាក់នៅ។ នៅថ្ងៃដដែលពេលយប់ឈ្មោះ វិន បានហៅខ្ញុំទៅរាំលេងនៅស្ប៉ាក ដោយមានគ្នា ១៥នាក់ ក្នុងនោះមានរូបខ្ញុំ ឈ្មោះ វិន ឈ្មោះ យ៉ា ផងដែរ។ ខ្ញុំបានបបួល យ៉ា ទៅរាំលេងដោយអ្នកផ្សេងទៀតរង្គុយនៅតុ ពេលខ្ញុំកំពុងរាំជាមួយ យ៉ា ក៏ស្រាប់តែឪពុក យ៉ា មកដល់ហើយនាំខ្ញុំបាទមកសមត្ថកិច្ចតែម្តង ដោយអ្នកផ្សេងទៀតមិនដឹងទៅណាអស់។

-ក្រឡាបញ្ជីអានចម្លើយរបស់សាក្សីឈ្មោះ [redacted] នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ថា : ខ្ញុំបាទបានស្គាល់ឈ្មោះ វិន នេះបានទើបតែរយៈពេលមួយខែ តាមរយៈទៅហូបចុកនៅហាងមួយនៅក្រុងភ្នំពេញហើយបានស្គាល់គ្នារាប់តាំងពីពេលនោះមក។ កន្លងមកពួកខ្ញុំបានដើរលេងជាមួយគ្នាម្តងម្កាល ទើបតែនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឈ្មោះ វិន នេះបានហៅខ្ញុំឱ្យទៅជួយទិញម៉ូតូវាប្រហែលម៉ោង ១០ ព្រឹក ខ្ញុំបានទៅ:



Scanned by CamScanner

ដល់តីរីវរបង្ក៏ឃើញមិត្តខ្ញុំឈ្មោះ វិន និងនារីម្នាក់ទៀតឈ្មោះ យ៉ា នោះនៅចាំខ្ញុំមិនអោះ ហើយក៏នាំគ្នាដើររកទិញម៉ូតូឱ្យឈ្មោះ យ៉ា គឺម៉ូតូម៉ាក ICON តម្លៃ ១៣៦០ដុល្លា ទិញរួចហើយខ្ញុំ និងឈ្មោះ វិន ឈ្មោះ យ៉ា ក៏មកផ្ទះមិត្តភក្តិម្នាក់ទៀតនៅខាងត្បូងផ្សារដើមគ គឺឈ្មោះ វុត្ថា ហើយឈ្មោះ វិន ទៅធ្វើការ ហើយឈ្មោះ យ៉ា បានតឹងខ្ញុំឱ្យជូនទៅទិញកាំងនៅផ្សារអូឬស្សីពិត ទិញហើយត្រឡប់មកផ្ទះឈ្មោះ វុត្ថា វិញ ឈ្មោះ វិន ក៏មកដល់ហើយនាំឈ្មោះ យ៉ា ទៅរកផ្ទះជួលនៅខាងកើតផ្សារអូឬស្សីពិត ។ ពេលល្ងាចឈ្មោះ វិន ក៏ហៅខ្ញុំទៅដើរលេងជាមួយរហូតដល់ម៉ោងប្រហែល ១០ យប់ ក៏នាំគ្នាចូលកាំលេងនៅស្ពាក ។ ឈ្មោះ យ៉ា និង វិន បានចុះមកកាំខាងក្រោមហើយក៏បាត់រហូត មិនឃើញទៅតុវិញ ។ នៅពេលព្រឹកឡើងថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឈ្មោះ វិន បានភ្ជាប់ការទាក់ទងនឹងអាយ៉ាវិញបាន ហើយ វិន ឱ្យខ្ញុំទៅជាមួយថា យកម៉ូតូទៅឱ្យ យ៉ា វិញ នៅខាងលិចផ្សារថ្មី ពេលទៅដល់ទីនោះក៏សមត្ថកិច្ចនាំខ្ញុំ និង វិន មកប៉ុស្តិ៍ ។

**-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា :** ឆ្លងតាមសវនាការ តំណាងអយ្យការយល់ឃើញថា នៅតែមានភស្តុតាងគ្រប់គ្រាន់លើឈ្មោ[redacted]រៈ ហៅ វិន ពីបទ រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ចេកមាស ក្រោយសាលាបាក់ទូក ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ តាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ ។ ហេតុនេះ តំណាងអយ្យការសុំតំកល់ការចោទប្រកាន់នៅដដែល ។

**-មេធាវីការពារជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា :** ឆ្លងតាមសវនាការ ទាក់ទិនលើការរួមភេទខ្ញុំយល់ឃើញថា ចម្លើយរបស់ជនរងគ្រោះនៅដំណាក់កាលសមត្ថកិច្ចថាខ្លួនបានរួមភេទពីរដង ប៉ុន្តែនៅដំណាក់កាលអយ្យការ និងចៅក្រមស៊ើបសួរគឺជនរងគ្រោះឆ្លើយថារួមភេទបួនដង ក្រោយពីធ្វើការរួមភេទហើយធ្វើឱ្យមានឈាមបណ្តាលដាច់សន្ទះព្រហ្មចារី ។ ក្នុងមួយយប់ជនរងគ្រោះរួមភេទបួនដង ។ នៅពេលធ្វើកោសលវិច័យគឺម្តាយរបស់ជនរងគ្រោះជូនទៅពិនិត្យ គឺគ្មានអ្នកណាក្លែងបន្លំទេ ហើយចំពោះចំណុច ១ និង ៦ ដែលបានបញ្ជាក់ថាពុំមានការរួមភេទទេ ។ ពេលជនរងគ្រោះទៅងូតទឹកគឺមានឈាម ប៉ុន្តែពេលធ្វើកោសលវិច័យ គឺគ្មានស្លាកស្នាមអ្វីទេ ។ តុលាការផ្អែកលើភស្តុតាង តែឥឡូវគឺគ្មានភស្តុតាងសំរាប់ដាក់បន្ទុកលើកូនក្តីខ្លួនទេ ដូចនេះវិមតិសង្ស័យត្រូវបានមកជនជាប់ចោទ ។ សំណូមពរ សុំឱ្យតុលាការដោះលែងកូនក្តីខ្លួនឱ្យរួចផុតពីបទចោទប្រកាន់ ។

**-ជនជាប់ចោទនិយាយសំដីចុងក្រោយថា :** សំណូមពរសុំឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផងដោយក្តីអនុគ្រោះ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។



Scanned by CamScanner

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារភស្តុតាង

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌមកជំនុំជម្រះពីបទ **រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ** ដែលមានជនជាប់ចោទឈ្មោះ [redacted] ហៅ វិន ភេទ ប្រុស អាយុ ២០ ឆ្នាំ ។ បទល្មើសនេះមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ ថា "ជនណារួមភេទជាមួយជនដទៃដែលមានអាយុតិចជាង ១៥ ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ឆ្នាំ ដល់ ១០ ឆ្នាំ ។"

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហៅ វិន នាពេលសវនាការថា នៅយប់ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ នោះខ្លួនពិតជាបានដេករួមបន្ទប់ជាមួយនឹងជនរងគ្រោះ នៅក្នុងផ្ទះសំណាក់ចេកមាស (ក្រោយសាលាបាក់ទូក) ពិតមែន ប៉ុន្តែខ្លួនមិនបានរួមភេទជាមួយជនរងគ្រោះទេ ហើយខ្លួនទៅដេកទីនោះដោយសារតែជនរងគ្រោះនិយាយថា មិនហ៊ានដេកម្នាក់ឯង ក៏ឱ្យខ្លួនទៅដេកជាមួយ លុះម៉ោង ៦ ជិតភ្លឺខ្លួនក៏ងើបឡើងទៅធ្វើការនៅបឹងសាឡាងវិញ ។ ប៉ុន្តែតាមចម្លើយរបស់ជនជាប់ចោទនៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងនៅមន្ត្រីនគរបាលយុត្តិធម៌សុទ្ធតែបានទទួលស្គាល់ថា ខ្លួនបានរួមភេទជាមួយនឹងជនរងគ្រោះឈ្មោះ [redacted] ចំនួន ០២ ដង នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ។

-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] បានឆ្លើយថា នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ខ្លួនបានមកភ្នំពេញ ដោយបានលួចយកខ្សែកម្តាយរបស់ខ្លួនមកលក់នៅផ្សារចន្លាប់ ពេលមកដល់ភ្នំពេញ ខ្លួនបានទូរស័ព្ទរកឈ្មោះ [redacted] ហៅ វិន ជនជាប់ចោទ ក្រោយមកឃើញជនជាប់ចោទមកទទួលខ្លួន ហើយបាននាំខ្លួនទៅជួលបន្ទប់នៅផ្ទះសំណាក់ចេកមាស (ក្រោយសាលាបាក់ទូក) ក្រោយមកបាននាំខ្លួនទៅទិញខោអាវនៅផ្សារសូរិយា រួចបន្តទៅហូបអីជាមួយមិត្តភក្តិរបស់ជនជាប់ចោទចំនួនប្រាំនាក់ទៀតនៅហាងរហូតដល់ម៉ោង ១១ យប់ បន្ទាប់មកក៏នាំគ្នាទៅក្លឹបឌីសស្កូរហូតដល់ម៉ោង ១២ ទើបចេញទៅផ្ទះសំណាក់ ពេលទៅដល់ផ្ទះសំណាក់ ខ្លួនក៏បានចូលទៅក្នុងបន្ទប់ ខ្លួនស្មានថាជនជាប់ចោទឱ្យខ្លួនដេកម្នាក់ឯង ខ្លួនក៏បិទទ្វារដោយមិនបានចាក់សោទេ ក្រោយមកជនជាប់ចោទក៏បានរុញទ្វារចូល ហើយបានរុញខ្លួនទៅលើគ្រែរួចចាប់ផ្តើមធ្វើសកម្មភាពរួមភេទរយៈពេល ១៥នាទី ទើបបញ្ចប់ ក្រោយមកប្រហែល ៥ នាទី ជនជាប់ចោទបានធ្វើសកម្មភាពរួមភេទមកលើខ្លួនពីរដងទៀត ក្រោយពីរួមភេទរួច ខ្លួនបានទៅបត់ទឹកក៏ឃើញមានឈាមហូរ បន្ទាប់មកនៅម៉ោងបីជិតភ្លឺជនជាប់ចោទបានធ្វើសកម្មភាពរួមភេទម្តងទៀតមកលើខ្លួន ។ ៚



Scanned by CamScanner

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] និងឈ្មោះ [redacted] ដែលត្រូវជាមិត្តភក្តិរបស់ជនជាប់ចោទ បានបញ្ជាក់ថា ក្រោយពេលដើរលេង និងហូបបាយរួចមក ខ្លួនបានបែកផ្លូវគ្នាទៅផ្ទះ ដោយឈ្មោះ វិន ( ជនជាប់ចោទ ) និងឈ្មោះ យ៉ា ( ជនរងគ្រោះ ) ទៅជាមួយគ្នា គឺទៅផ្ទះសំណាក់ដែលពួកគេបានជួលទុក ។

-តាមចម្លើយរបស់ជនរងគ្រោះ ជនជាប់ចោទ និងសាក្សី មានលក្ខណៈស៊ីសង្វាក់គ្នា ដែលបង្ហាញឱ្យតុលាការជឿថា ជនជាប់ចោទឈ្មោះ [redacted] វីរៈ ហៅ វិន ពិតជាបាននៅជាមួយជនរងគ្រោះ ហើយបានរួមភេទជាមួយជនរងគ្រោះប្រាកដមែន ។ ចំណែកឯចម្លើយរបស់ជនជាប់ចោទនាពេលក្រោយ ដែលថាពុំបានរួមភេទជាមួយនឹងជនរងគ្រោះ ពុំអាចឱ្យតុលាការជឿបានទេ ព្រោះថា នៅយប់ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ជនជាប់ចោទនិងជនរងគ្រោះស្នាក់នៅក្នុងបន្ទប់តែមួយជាមួយគ្នា ហើយជនជាប់ចោទបានឆ្លើយសារភាពនៅដំណាក់កាលមុន១នៃនីតិវិធីថា ពិតជាបានរួមភេទជាមួយនឹងជនរងគ្រោះមែន ។ ជាពិសេសចម្លើយរបស់សាក្សីឈ្មោះ [redacted] បានបញ្ជាក់ពីលិខិតកោសលវិច័យពេទ្យចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១០ របស់មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញថា ការរួមភេទក៏អាចមិនធ្វើឱ្យដាច់សន្ទះព្រហ្មចារី បើភាគីប្រើប្រាស់បច្ចេកទេសក្នុងការរួមភេទ ។ តាមឯកសារពិនិត្យការរំលោភផ្លូវភេទលេខ ០៨/១០ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១០ របស់មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ បានបញ្ជាក់ថា ជនរងគ្រោះមានសន្ទះ ព្រហ្មចារីល្អ ។ ហេតុនេះ ទោះបីជាជនរងគ្រោះពុំបានដាច់សន្ទះព្រហ្មចារីក៏ដោយ ក៏ពុំមែនបញ្ជាក់ថា ពុំមានការរួមភេទរវាងជនជាប់ចោទ និងជនរងគ្រោះដែរ ។

-តាមសំបុត្របញ្ជាក់កំណើតលេខ ៦៧៩៣ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៥ ឃើញថា ឈ្មោះ [redacted] យ៉ា កើតនៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ គឺមានអាយុ ១៤ ឆ្នាំ នៅឡើយ គិតមកដល់ថ្ងៃកើតហេតុ ។

-តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទថា ពុំមានភស្តុតាងសំរាប់ដាក់បន្ទុកលើកូនក្តីរបស់ខ្លួនទេ ហើយសំណូមពរសុំឱ្យតុលាការដោះលែងកូនក្តីខ្លួនឱ្យរួចផុតពីបទចោទប្រកាន់ គឺពុំត្រឹមត្រូវទេ ព្រោះថា ចម្លើយរបស់ជនរងគ្រោះ ជនជាប់ចោទនៅមន្ត្រីនគរបាលយុត្តិធម៌ និងអយ្យការ មានលក្ខណៈគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទ ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការនាពេលសវនាការដែលស្នើសុំតំកល់ការចោទប្រកាន់ដដែលមានលក្ខណៈត្រឹមត្រូវ ។

-ជនជាប់ចោទជានីតិជន មានសមត្ថភាពដឹងខុសត្រូវធម្មតា អាចឱ្យទទួលខុសត្រូវព្រហ្មទណ្ឌបាន ។

-មានភស្តុតាងដាក់បន្ទុក និងមានពិរុទ្ធភាពគ្រប់គ្រាន់ទៅលើឈ្មោះ [redacted] **វីរៈ ហៅ វិន** ពីបទ រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ចេកមាស ( ក្រោយសាលាបាក់ទូក) ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ តាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

-ជនជាប់ចោទស្ថិតនៅក្នុងយុវភាពនៅឡើយ និងទើបប្រព្រឹត្តបទល្មើសជាលើកទីមួយ ។



Scanned by CamScanner

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ដែលត្រូវជាម្ដាយរបស់ជនរងគ្រោះបានទាមទារសំណងជំងឺចិត្ត ១០ ០០០ ដុល្លា ពីជនជាប់ចោទ ។ ប៉ុន្តែដើមបណ្ដឹងរដ្ឋប្បវេណីពុំបានផ្ដល់ឯកសារភស្ដុតាងពីទំហំនៃការខូចខាតមកតុលាការទេ ។ ហើយម្យ៉ាងវិញទៀត គឺជនរងគ្រោះដែលយកទ្រព្យសម្បត្តិរបស់ឪពុកម្ដាយមកដើរចាយវាយជាមួយនឹងជនជាប់ចោទដោយខ្លួនឯង ពោលគឺអំពើរបស់ជនជាប់ចោទពុំប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទេ គ្រាន់តែប៉ះពាល់ដល់រាងកាយរបស់ជនរងគ្រោះប៉ុណ្ណោះ ។ ហេតុនេះ តុលាការសម្រេចតាមភាពសមរម្យជាក់ស្ដែង ។

## ហេតុដូច្នេះសម្រេច

១-ផ្ដន្ទាទោសឈ្មោះ [redacted] ហៅ វិន ភេទប្រុស អាយុ ២០ ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៥ ឆ្នាំ ( ប្រាំឆ្នាំ ) ពីបទ **រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ** ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ចេកមាស ( ក្រោយសាលាបាក់ទូក ) ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ តាមមាត្រា ៤២ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

២-បង្គាប់ឱ្យឈ្មោះ [redacted] **ហៅ វិន** បង់ប្រាក់សំណងជម្ងឺចិត្តចំនួន ៤ ០០០ ០០០ **រៀល ( បួនលានរៀល )** ឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ។ ការទាមទារលើសពីនេះត្រូវច្រានចោល ។

៣-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១០ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហៅ វិន មេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] និងជនរងគ្រោះឈ្មោះ [redacted] បើកផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។ ៚

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា : [redacted] | ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
... 03 ឆ្នាំ ២០១១
ក្រឡាបញ្ជី
[redacted]



Scanned by CamScanner